01086478

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 17 / 04 / 2015
ម៉ោង (Time/Heure): 09:25
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

002/19-09-2007-ECCC/TC
**E1/283**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ ព្រហស្បតិ៍ ទី ២៦ ខែ មីនា ឆ្នាំ ២០១៥

## **សវនាការលើភ័ស្តុតាង - ថ្ងៃ ២៦៤**

រៀបចំដោយ៖ **ជា ស៊ីវហ័ង** និង **Matthew McCARTHY**

| **កំណត់ហេតុអ្នកចូលរួម** |
|---|
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យ៉ា សុខន, ចៅក្រម Claudia FENZ, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី, ចៅក្រម Martin KAROPKIN |
| ក្រឡាបញ្ជី៖ កញ្ញា ជា ស៊ីវហ័ង, លោក Matthew McCARTHY |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក សេង ប៊ុនឃាង, លោក ស្រ៊ា រតនៈ, លោក Vincent de Wilde d'ESTMAEL |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួន), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ នួន ជា៖ លោក សួន វិសាល, លោក Victor KOPPE |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSE |
| ក្រុមមេធាវីប្រចាំការសម្រាប់ជនជាប់ចោទ ខៀវ សំផន៖ លោកស្រី ទូច វរល័ក្ស, លោក Calvin SAUNDERS |
| មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖ លោកស្រី Marie GUIRAUD |
| សាក្សី/ដើមបណ្ដឹង៖ អ៊ឹម សារឿន (2-TCCP-980) |

| |
|---|
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អរុណ, លោកស្រី សួ សុទ្ធាវី |
| ផ្សេងៗ៖ កញ្ញា ណើ សុមេត្តា, លោក វ៉ាត សុម៉ៅ, លោក ហ៊្វ ជីសេង, លោក Mr. Yassir AL-KHUDAYRI |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៥ | ចាប់ផ្ដើមម៉ោង៖ ០៩.០០ | បញ្ចប់ម៉ោង៖១២.១៥ |
| សម្រាកពេលព្រឹក | ចាប់ផ្ដើមម៉ោង៖ ១០.១៥ | បញ្ចប់ម៉ោង៖១០.៣១ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្ដើមម៉ោង៖ គ្មាន | បញ្ចប់ម៉ោង៖ គ្មាន |
| សម្រាកពេលរសៀល | ចាប់ផ្ដើមម៉ោង៖ គ្មាន | បញ្ចប់ម៉ោង៖ គ្មាន |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ០២ ម៉ោង និង ៥៩ នាទី |

**កិច្ចដំណើរការនីតិវិធីផ្សេងទៀត**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្ដើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី | អង្គជំនុំជម្រះ<br>ក្រឡាបញ្ជី | ០៩.០០ | ០៩.០៣ |
| សំណើរបស់ នួន ជា ស្នើសុំតាមដានកិច្ចដំណើការនីតិវិធីពីបន្ទប់ឃុំខ្លួនក្រោមសាលសវនាការ | មេធាវីការពារក្ដី នួន ជា | ០៩.០៣ | ០៩.០៤ |
| ការតាំងសំណួរទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ឹម សារឿន (2-TCCP-980) | អង្គជំនុំជម្រះ<br><br>សហមេធាវីនាំមុខ<br>សហព្រះរាជអាជ្ញា<br>មេធាវីការពារក្ដី នួន ជា<br>មេធាវីការពារក្ដី ខៀវ សំផន<br>ដើមបណ្ដឹងរដ្ឋប្បវេណី (ថ្លែងរៀបរាប់ទុក្ខសោក) | ០៩.០៧<br>១០.៣២<br>០៩.១៣<br>០៩.៥៤<br>១០.៥៩<br>១១.២៦<br>១២.០៤ | ០៩.១២<br>១០.៥៩<br>០៩.៥៤<br>១០.១៥<br>១១.២៦<br>១២.០៣<br>១២.០៧ |
| សំណើរបស់មេធាវីការពារក្ដី នួន ជា ស្នើឱ្យមានការបំភ្លឺទាក់ទងនឹងការសួរដេញដោលសាក្សី Richard DUDMAN (2-TCW-923) | មេធាវីការពារក្ដី នួន ជា | ១២.០៩ | ១២.១៣ |

**<u>សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

**<u>ការប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី</u>**

ប្រធានអង្គជំនុំជម្រះប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ។ ក្រឡាបញ្ជីរាយការណ៍ថា គ្រប់ភាគីទាំងអស់មានវត្តមាន។ ជនជាប់ចោទ នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួន ក្រោមសាលសវនាការ។

**<u>សំណើរបស់ នួន ជា ស្នើសុំតាមដានកិច្ចដំណើការនីតិវិធីពីបន្ទប់ឃុំខ្លួនក្រោមសាលសវនាការ</u>**

អង្គជំនុំជម្រះសម្រេចអនុញ្ញាតតាមសំណើរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមកិច្ចដំណើរការនីតិវិធីដោយផ្ទាល់ក្នុងសាលសវនាការ និងអនុញ្ញាតឱ្យគាត់តាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួន ស្ថិតនៅខាងក្រោមសាលសវនាការ។

**<u>ការតាំងសំណួរទៅកាន់សាក្សី អ៊ុម សារឿន (2-TCCP-980)</u>**

អង្គជំនុំជម្រះ សហមេធាវីនាំមុខ សហព្រះរាជអាជ្ញា មេធាវីការពារក្តី នួន ជា និង មេធាវីការពារក្តី ខៀវ សំផន បានធ្វើការតាំងសំណួរទៅសាក្សី អ៊ុម សារឿន (2-TCCP-980)។

**<u>សំណើរបស់មេធាវីការពារក្តី នួន ជា ស្នើសុំដាក់បង្ហាញផ្ទាំងរូបថត ទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុម សារឿន (2-TCCP-980)</u>**

មេធាវីការពារក្តី នួន ជា បានបង្ហាញផ្ទាំងរូបថតទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុម សារឿន (2-TCCP-980) ដែលក្នុងនោះមានរូបភាពបុគ្គលចំនួន ១០ រូប (ផ្ទាំងរូបថតមានភ្ជាប់ជាមួយនឹងកំណត់ហេតុនេះ) ។ មន្ត្រីរដ្ឋបាលតុលាការបានយកផ្ទាំងរូបថតនោះទៅជូនដើមបណ្តឹងរដ្ឋប្បវេណី។ មេធាវីការពារក្តី នួន ជា និងអង្គជំនុំជម្រះបានឱ្យដើមបណ្តឹងរដ្ឋប្បវេណី អ៊ុម សារឿន ចង្អុលបង្ហាញថាតើរូបណាមួយក្នុងចំណោមរូបបុគ្គលទាំងនោះ ជារូប តាម៉ុក។

**<u>សំណើរបស់មេធាវីការពារក្តី នួន ជា ស្នើឱ្យមានការបំភ្លឺទាក់ទងនឹងការសួរដេញដោលសាក្សី Richard DUDMAN (2-TCW-923)</u>**

មេធាវីការពារក្តី នួន ជា បានស្នើសុំឱ្យអង្គជំនុំជម្រះបំភ្លឺទាក់ទងទៅនឹងការផ្លាស់ប្តូរលំដាប់លំដោយក្នុងការសួរដេញដោលសាក្សី Richard DUDMAN (2-TCW-923) នៅថ្ងៃទី ៣០ ខែមីនា ឆ្នាំ ២០១៥។ សហព្រះរាជអាជ្ញា និង សហមេធាវីនាំមុខ ពុំបានធ្វើការជំទាស់ទៅនឹងលំដាប់លំដោយក្នុងការតាំងសំណួរនោះទេ។ អង្គជំនុំជម្រះនឹងចេញសេចក្តីសម្រេចជាក់ស្តែងលើបញ្ហានេះនៅថ្ងៃ ចន្ទ ទី៣០ ខែ មីនា ឆ្នាំ ២០១៥។

01086481



**<u>កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង</u>**

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/5869 | D22/2500 | 00550905-00550916; 01069306-01069307 | Civil party application of UNG Saroeun 10-VU-00020 | P | 00550905 00550909 | 01069306 | N/A |
| E3/5870 | D22/2500a | 00587133-00587134 | ឯកសារបន្ថែមរបស់ដើមបណ្តឹងរដ្ឋប្បវេណី | P | 00587133 00587134 | N/A | N/A |
| E3/5871 | D22/2500b | 00594688-00594689 | Summary of the supplementary information of civil party applicant | P | N/A | 00594688 00594689 | N/A |
| E3/3091R | | V00172427 | Video entitled "What has happened to Cambodia: Ronnie Yimsut's story" | P | N/A | 43:13 43:27 43:34 43:35 43:57 | N/A |
| E3/5872 | D22/2500/1 | 00550902-00550904 | Report on Civil Party Application | P | N/A | 00550904 | N/A |
| E3/44.1 | | 01075946-01075948; 01075928-01075930 | Supplementary information on crimes of civil party Mrs UNG Saroeun (D22/2500) | P | | | N/A |

**<u>ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖</u>**

- អនុញ្ញាតឱ្យជនជាប់ចោទ នួន ជា បន្តតាមដានកិច្ចដំណើរការនីតិវិធីសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួន ខាងក្រោមសាលសវនាការ ហើយបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា ដើម្បីតាមដានសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។
- បង្គាប់ឱ្យមន្ត្រីរដ្ឋបាលតុលាការយកផ្ទាំងរូបថតទៅជូនដើមបណ្តឹងរដ្ឋប្បវេណី អ៊ុម សារឿន (2-TCCP-980) ដើម្បីឱ្យគាត់ចង្អុលបង្ហាញ។
- អង្គជំនុំជម្រះនឹងសម្រេចលើសំណើរបស់ នួន ជា ដែលបានស្នើសុំបញ្ជាក់ពីលំដាប់លំដោយនៃការសួរសាក្សី Richard DUDMAN (2-TCW-923) នៅថ្ងៃ ចន្ទ ទី ៣០ ខែ មីនា ឆ្នាំ ២០១៥។
- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ត្រឡប់ទៅមន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំខ្លួនគាត់ មកសាលសវនាការវិញឱ្យបានមុនម៉ោង ០៨.០០ ព្រឹក នៅថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៥ ។

01086482



| **<u>កាលវេលាសវនាការបន្ត</u>** |
| --- |
| សវនាការនឹងបន្តទៅថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៥ ចាប់ផ្តើមពីម៉ោង ០៨.០០ ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៥

ក្រឡាបញ្ជី ក្រឡាបញ្ជី

**ជា ស៊ីថប** **Matthew McCARTHY**